**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខៈ ......ន. គ. ស,

ថ្ងៃ ចន្ទ ១១ កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសទីប្រឹក្សាបច្ចេកទេសក្នុងស្រុក ដើម្បីជួយលើការងារបច្ចេកទេសស្តង់ដា និងអនុលោមភាព ការងារត្រួតពិនិត្យគុណភាពសវនកម្ម និងការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

**និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស.**) គឺជាស្ថាប័នតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស.** បានដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល១០ឆ្នាំ (២០២១ -២០៣០) និងបានរៀបចំនូវសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មរយៈពេល ១០ឆ្នាំ (២០២១ -២០៣០) ដែលនឹងត្រូវដាក់ឱ្យអនុវត្តក្នុងពេលឆាប់ៗនេះ។ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់កម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុ, ការរៀបចំស្តង់ដាគណនេយ្យ, ការកសាងមូលធនមនុស្សជំនាញគណនេយ្យនិងសវនកម្មសម្រាប់ទីផ្សារ, ការលើកកម្ពស់គុណភាពសេវាគណនេយ្យនិងសវនកម្ម និងសេវាអះអាងពាក់ព័ន្ធ **ន.គ.ស.** ត្រូវការជ្រើសរើសទីប្រឹក្សាក្នុងស្រុកចំនួន៣ (បី) រូប ដែលមានគុណវុឌ្ឍិខ្ពស់ ដើម្បីជាជំនួយបច្ចេកទេសលើការងារអាទិភាពចំនួន៣ គឺការងារបច្ចេកទេសស្តង់ដានិងអនុលោមភាព, ការងារត្រួតពិនិត្យគុណភាពសវនកម្ម និងការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសទីប្រឹក្សាចំនួន៣ (បី) រូប ដែលមានគុណវុឌ្ឍិដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

#### ១.១. ការងារបច្ចេកទេសស្តង់ដា និងអនុលោមភាព

- ជាគណនេយ្យករជំនាញ (ACCA, CPA Australia, KICPAA ឬស្ថាប័នដែលទទួលស្គាល់ផ្សេងទៀត)
- ជាសមាជិកគណនេយ្យករជំនាញរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(KICPAA) និង ស្ថាប័នអន្តរជាតិ
- មានបទពិសោធន៍យ៉ាងតិច ១៥ ឆ្នាំ ក្នុងវិស័យគណនេយ្យនិងសវនកម្ម
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត
- ជាបុគ្គលវិជ្ជមាន, មានសមត្ថភាពគ្រប់គ្រងការងារដោយខ្លួនឯង និងមានទំនាក់ទំនងល្អប្រសើរ
- មានកម្រិតភាសាអង់គ្លេសស្ទាត់ជំនាញ។

#### ១.២. ការងារត្រួតពិនិត្យគុណភាពសវនកម្ម

- ជាគណនេយ្យករជំនាញ (ACCA, CPA Australia, KICPAA ឬស្ថាប័នដែលទទួលស្គាល់ផ្សេងទៀត)
- ជាសមាជិកគណនេយ្យករជំនាញរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(KICPAA) និង ស្ថាប័នអន្តរជាតិ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារសវនកម្មរយៈពេលយ៉ាងតិច១០ឆ្នាំ
- មានចំណេះដឹង និងបទពិសោធន៍ការអនុវត្តលើ IFRS Audit Quality (ISQM1 / ISQM2)

- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត
- ជាបុគ្គលវិជ្ជមាន, មានសមត្ថភាពគ្រប់គ្រងការងារដោយខ្លួនឯង និងមានទំនាក់ទំនងល្អប្រសើរ
- មានកម្រិតភាសាអង់គ្លេសស្ទាត់ជំនាញ។

**១.៣. ការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា**

- ជាគណនេយ្យករជំនាញ (ACCA, CPA Australia, KICPAA ឬស្ថាប័នដែលទទួលស្គាល់ផ្សេងទៀត)
- ជាសមាជិកគណនេយ្យករជំនាញរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(KICPAA) និង ស្ថាប័នអន្តរជាតិ
- មានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការងារសិក្សាគណនេយ្យយ៉ាងតិច ១៥ ឆ្នាំ
- មានចំណេះដឹង និងបទពិសោធន៍ការអនុវត្តលើ CPA
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត
- ជាបុគ្គលវិជ្ជមាន, មានសមត្ថភាពគ្រប់គ្រងការងារដោយខ្លួនឯង និងមានទំនាក់ទំនងល្អប្រសើរ
- មានកម្រិតភាសាអង់គ្លេសស្ទាត់ជំនាញ។

## ២. លក្ខខណ្ឌយោងការងារ

### ២.១. ការងារបច្ចេកទេសស្តង់ដា និងអនុលោមភាព

**❖ ការងារអនុលោមភាព**

- ផ្តល់ប្រឹក្សាយោបល់ និងចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្ត, យុទ្ធសាស្ត្រនិងគោលការណ៍ត្រួតពិនិត្យ និងវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ផ្តល់នូវការបណ្តុះបណ្តាលពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យពាក់ព័ន្ធ នឹងការអនុវត្តសាកល្បងការត្រួតពិនិត្យកម្រិតអនុលោមភាពបច្ចេកទេស
- ផ្តល់នូវការបណ្តុះបណ្តាលលើនីតិវិធី និងបច្ចេកទេសក្នុងការពិនិត្យ និងវាយតម្លៃកម្រិតអនុលោមភាព នៃរបាយការណ៍ហិរញ្ញវត្ថុចំពោះស្តង់ដាគណនេយ្យស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- រៀបចំសៀវភៅណែនាំសម្រាប់ការពិនិត្យ និងវាយតម្លៃកម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុចំពោះស្តង់ដាគណនេយ្យស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- ផ្តល់ប្រឹក្សាយោបល់ និងដឹកនាំរៀបចំ និងគ្រប់គ្រងទិន្នន័យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ផ្តល់ប្រឹក្សាយោបល់ និងចូលរួមរៀបចំការបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធកិច្ចការពាក់ព័ន្ធផ្សេងៗ។

**❖ ការងារស្តង់ដាគណនេយ្យ**

- រៀបចំរបាយការណ៍ឧត្តមានុវត្តន៍នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុសាមញ្ញដែលបានអនុវត្តក្នុងតំបន់និងសកល
- រៀបចំតារាងប្រៀបធៀបស្តង់ដា CIFRS for SMEs ជាមួយស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា
- សិក្សាស្រាវជ្រាវអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការដាក់អនុវត្តស្តង់ដាគណនេយ្យសាមញ្ញដល់សហគ្រាស
- ពិនិត្យទៅលើច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្ត ដែលជាប់ពាក់ព័ន្ធជាមួយស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា។

### ២.២. ការងារត្រួតពិនិត្យគុណភាពសវនកម្ម

- ត្រូវផ្តល់នូវការបណ្តុះបណ្តាលពាក់ព័ន្ធនឹង IFRS Audit Quality (ISQM1 / ISQM2)
- ត្រូវផ្តល់នូវការបណ្តុះបណ្តាលលើនីតិវិធីនៃការរៀបចំសៀវភៅណែនាំស្តីពីការងារសវនកម្ម
- ត្រូវផ្តល់នូវការបណ្តុះបណ្តាលលើនីតិវិធីលម្អិតលើការចុះត្រួតពិនិត្យគុណភាពសវនកម្មលើក្រុមហ៊ុនសវនកម្ម
- ត្រូវផ្តល់នូវការចុះអនុវត្តជាក់ស្តែងលើការចុះត្រួតពិនិត្យគុណភាពសវនកម្ម និង
- ត្រូវដឹកនាំក្រុមការងារត្រួតពិនិត្យក្នុងការចុះត្រួតពិនិត្យគុណភាពសវនកម្ម។

## ២.៣. ការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

ក្នុងកំឡុងពេលនៃការអនុវត្តការងារនេះ ទីប្រឹក្សាមានទំនួលខុសត្រូវ អនុវត្តមុខងារនិងភារកិច្ចរបស់លេខាធិការដ្ឋាន ដោយបំពេញមុខងារជាសេនាធិការ គ.ក.គ.ល អនុគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា, អនុគណៈកម្មការគ្រប់គ្រងការប្រឡង និងអនុគណៈកម្មការទទួលស្គាល់អប់រំ និងការបណ្តុះបណ្តាលលើការងារបច្ចេកទេសដូចខាងក្រោម÷

- ធ្វើការវាយតម្លៃយ៉ាងហ្មត់ចត់ចំពោះ កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដែលមានស្រាប់ រួមទាំងការវាយតម្លៃស៊ីជម្រៅលើកម្មវិធីសិក្សា រចនាសម្ព័ន្ធប្រឡង និងលក្ខណៈវិនិច្ឆយក្នុងការទទួលវិញ្ញាបនបត្រ
- វាយតម្លៃកម្មវិធីសិក្សាឱ្យស្របទៅនឹងស្តង់ដាគណនេយ្យ និងសវនកម្មអន្តរជាតិ ក្របខ័ណ្ឌបទប្បញ្ញត្តិ និងនិន្នាការថ្មីៗ
- ផ្តល់ដំបូន្មាន អនុសាសន៍ និងយុទ្ធសាស្រ្តដែលចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាព និងភាពពាក់ព័ន្ធនៃកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ផ្តល់ប្រឹក្សាលើការបង្កើតឯកសារសិក្សា និងការប្រឡង ដើម្បីឱ្យមានភាពសមស្របទៅនឹងគោលបំណងស្តង់ដា និងតម្រូវការរបស់កម្មវិធីសិក្សារបស់គណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ផ្តល់ប្រឹក្សាលើការរចនា និងវឌ្ឍនភាពនៃកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) ដែលរួមមានការកំណត់បទពិសោធន៍ជាក់ស្តែងដែលចាំបាច់សម្រាប់ការបញ្ចប់ការសិក្សាដោយជោគជ័យ
- ណែនាំអំពីរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុងសម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាដោយធានាថាកម្មវិធីសិក្សាដំណើរការប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់
- សហការជាមួយគណៈកម្មាធិការលើការវាយតម្លៃចំពោះកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាឲ្យស្របទៅនឹងស្តង់ដាទទួលស្គាល់ជាអន្តរជាតិ ក៏ដូចជាក្របខ័ណ្ឌបទប្បញ្ញត្តិនានា និងនិន្នាការថ្មីៗ
- ចូលរួមធ្វើការវាយតម្លៃ ជ្រើសរើស និងវាស់វែងចំពោះគុណភាព ការអនុវត្ត និងប្រសិទ្ធភាពរបស់ស្ថាប័នបណ្តុះបណ្តាល
- ជំរុញទំនាក់ទំនង និងកិច្ចសហការរវាងគណៈកម្មាធិការជាមួយ អ្នកជំនាញគណនេយ្យ ស្ថាប័នបណ្តុះបណ្តាល និងស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ធ្វើការជាមួយស្ថាប័នជំនាញ ដើម្បីអភិវឌ្ឍកម្មវិធីក្នុងស្រុក តំបន់ និងអន្តរជាតិ
- ណែនាំអំពីយុទ្ធសាស្រ្តឆ្ពោះទៅទីផ្សារ (GTM) ដើម្បីសហការជាមួយអ្នកផ្តល់សេវាបណ្តុះបណ្តាល និងភាគីពាក់ព័ន្ធផ្សេងទៀត និងផ្សព្វផ្សាយកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

## ៣. ការរាយការណ៍

ទីប្រឹក្សា នឹងត្រូវធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារប្រចាំត្រីមាស និងដំណាច់ឆ្នាំជូនអគ្គនាយក **ន.គ.ស.**។

## ៤. រយៈពេលធ្វើការ

ទីប្រឹក្សាទាំង៣ (បី)រូប សម្រាប់ការងារខាងលើនេះ គឺត្រូវចុះកិច្ចសន្យាជាមួយ **ន.គ.ស.** ដែលមានរយៈពេលការងារចំនួន ២៤ខែ ឬអាចតាមរយៈពេលកំណត់មួយដោយយោងលើភាពចាំបាច់ និងកិច្ចព្រមព្រៀងរវាងទ្វេរភាគី។

## ៥. មធ្យោបាយភាសា

ភាសាខ្មែរ និង/ឬ ភាសាអង់គ្លេសត្រូវបានប្រើប្រាស់សម្រាប់ការទំនាក់ទំនងការរៀបចំរបាយការណ៍ និងឯកសារផ្សេងៗ។

## ៦. ការរៀបចំឡជីស្ទីក

កៅអី និងតុការិយាល័យ ប្រព័ន្ធអ៊ីនធឺណែត និងសម្ភារៈផ្គត់ផ្គង់ការិយាល័យផ្សេងៗទៀតនឹងត្រូវផ្តល់ជូនទីប្រឹក្សា។ ទីប្រឹក្សាមិនបានលើកទឹកចិត្តឱ្យធ្វើការ ឬទំនាក់ទំនងសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួនក្នុងកំឡុងពេលធ្វើការនោះទេ។

## ៧. កម្រៃ

កម្រៃដែលទាក់ទងនឹងការងារនេះ គឺបើកចំហរសម្រាប់ការចរចា។

Ly 8

**៨. ការដាក់ពាក្យ**

ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **គ.គ.ស.** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh ត្រឹមថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០២៤ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ “ក” ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ÷ ០៦៩ ៧៨៣ ៩៣៦ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**